អ៊ិនធើណេសិនណល ស្គូល អហ្វ សៀមរាប

International School of Siem Reap




# ព័ត៌មានអំពីសាលាបឋមសិក្សាប្រចាំ ខែមិថុនា ឆ្នាំ២០២២

## វិស្សមកាលឆ្នាំសិក្សា ២០២១-២០២២ជិតមកដល់!




ឆ្នាំសិក្សា២០២១-២០២២បានបញ្ចប់ យើងខ្ញុំពិតជាមោទនភាពចំពោះការប្រឹងប្រែងរបស់សិស្សានុសិស្ស លោកគ្រូអ្នកគ្រូទាំងអស់។ រយៈពេល២ឆ្នាំកន្លងទៅនេះ សាលាបានស្វែងរកវិធីសាស្ត្រដើម្បីជួយឲ្យកូនៗសិស្សានុសិស្សទទួលបាននូវការអប់រំមួយដ៏ត្រឹមត្រូវ ទោះបីស្ថិតក្រោមបរិបទនៃការរីករាលដាលនៃជំងឺកូវីដ១៩។ ជាលទ្ធផលសិស្សានុសិស្សទាំងអស់បានខិតខំប្រឹងប្រែងរៀនសូត្រគ្រប់មុខវិជ្ជា និងទទួលបានលទ្ធផលល្អ។ យើងខ្ញុំសូមជូនពរដល់សិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ បុគ្គលិក និងក្រុមគ្រួសារទទួលបាននូវភាពរីករាយក្នុងថ្ងៃឈប់សម្រាក។ យើងនឹងជួបគ្នាម្តងទៀតនៅថ្ងៃ**ចន្ទ ទី១៥ ខែសីហា ឆ្នាំ២០២២ សម្រាប់ឆ្នាំសិក្សាថ្មីខាងមុខនេះ។**








នៅក្នុងខែមិថុនានេះផងដែរ សាលាISSRផ្នែកបឋមសិក្សាកំពុងរៀបចំបង្កើតទីតាំងលេងកម្សាន្តថ្មី (កន្លែងអានសៀវភៅ ទោងយោល ភ្នំខ្សាច់ ជាដើម) ដែលជាទីតាំងសម្រាប់បង្រៀនសកម្មភាពក្រៅថ្នាក់ដល់កូនៗសិស្សានុសិស្ស។ កន្លែងកម្សាន្តលេងថ្មីនេះនឹងចាប់ផ្តើមដំណើរការនៅឆ្នាំសិក្សាថ្មី២០២២-២០២៣។




សូមអបអរសាទរសិស្សានុសិស្សថ្នាក់ទី៦ ផ្នែកបឋមសិក្សានៃសាលាISSR បានបញ្ចប់ឆ្នាំសិក្សាដោយជោគជ័យ និងសិស្សភាគច្រើនទទួលបានលទ្ធផលល្អក្នុងការសិក្សា ព្រមទាំងបានឡើងថ្នាក់ទី៧ផ្នែកវិទ្យាល័យនៅឆ្នាំសិក្សាថ្មី២០២២-២០២៣ខាងមុខនេះ។ សូមជូនពរពួកគេទទួលបានសំណាងល្អនៅឆ្នាំថ្មី។








អ៊ិនធើណេសិនណល ស្គូល អហ្វ សៀមរាប

International School of Siem Reap




# ព័ត៌មានអំពីសាលាបឋមសិក្សាប្រចាំ ខែមិថុនា ឆ្នាំ២០២២

ក្នុងវិស្សមកាលនេះមានលោកគ្រូ អ្នកគ្រូខ្លះបានលាឈប់ពីការងារដើម្បីវិលត្រឡប់ទៅស្រុកកំណើត និងផ្លាស់ទីកន្លែងការងារថ្មី អរគុណពួកគាត់ដែលបានប្រឹងប្រែងជួយបង្ហាត់បង្រៀនសិស្សប្រកបដោយគុណភាពជាពិសេសក្នុងកំឡុងនៃការរីករាលដាលនៃជំងឺកូវីដ១៩ កន្លងមក។ សូមជូនពរពួកគាត់ជួបប្រទះសំណាងល្អគ្រប់ពេល និងសង្ឃឹមថាពួកគាត់នឹងនៅបន្តទំនាក់ទំនងល្អជាមួយសាលានាថ្ងៃអនាគត។ ខាងក្រោមនេះគឺជាបញ្ជីឈ្មោះលោកគ្រូ អ្នកគ្រូដែលនឹងបង្រៀនកូនៗសិស្សានុសិស្សនៅឆ្នាំសិក្សាថ្មី។ សាលារីករាយ និងសូមស្វាគមន៍ដល់ការចូលរួមបំពេញការងាររបស់ពួកគាត់ទាំងអស់គ្នានៅសាលាISSR។

| ថ្នាក់រៀន ឆ្នាំសិក្សា២០២១-២០២២ | ត្រូវចូលសិក្សាថ្មី ២០២២-២០២៣ | លោកគ្រូ អ្នកគ្រូ |
|---|---|---|
| | មត្តេយ្យកម្រិតទាប (Nursery) | អ្នកគ្រូ Rita |
| មត្តេយ្យកម្រិតទាប (Nursery) | មត្តេយ្យកម្រិតមធ្យម (Reception 1) | អ្នកគ្រូ Janica |
| មត្តេយ្យកម្រិតមធ្យម (Reception 1) | មត្តេយ្យកម្រិតខ្ពស់ (Reception 2) | អ្នកគ្រូ Sally |
| មត្តេយ្យកម្រិតខ្ពស់ (Reception 2) | ថ្នាក់ទី១ A និងថ្នាក់ទី១ B | អ្នកគ្រូ Caryl និងអ្នកគ្រូ Katie |
| ថ្នាក់ទី១ | ថ្នាក់ទី២ | អ្នកគ្រូ Melanie |
| ថ្នាក់ទី២ | ថ្នាក់ទី៣ | លោកគ្រូ Philip |
| ថ្នាក់ទី៣ | ថ្នាក់ទី៤ | អ្នកគ្រូ Heather |
| ថ្នាក់ទី៤ A | ថ្នាក់ទី៥ A | អ្នកគ្រូ Dimple |
| ថ្នាក់ទី៤B | ថ្នាក់ទី៥ B | TBC |
| ថ្នាក់ទី៥ | ថ្នាក់ទី៦ | អ្នកគ្រូ Gloria |

សូមស្វាគមន៍ដល់លោក David Key នឹងមកកាន់មុខតំណែងជានាយកកម្មវិធីសិក្សាផ្នែកអន្តរជាតិ នៅសាលាISSR ផ្នែកបឋមនៅខែសីហាខាងមុខនេះ។ លោកDavid Key មានបទពិសោធន៍ជានាយកសាលាជាច្រើនឆ្នាំ មិនតែប៉ុណ្ណោះគាត់មានបទពិសោធន៍បង្រៀនសិស្សអស់រយៈពេលជាង៤០ឆ្នាំ។ ម្យ៉ាងវិញទៀតគាត់មានបទពិសោធន៍ក្នុងការគ្រប់គ្រងកម្មវិធីសិក្សារបស់ប្រទេសអង់គ្លេសផងដែរ។



កម្មវិធីតន្ត្រីបញ្ចប់ឆ្នាំសិក្សារបស់សាលានឹងប្រព្រឹត្តទៅនៅ**ថ្ងៃសុក្រ ទី២៤ ខែមិថុនា វេលាម៉ោង៨.៣០ព្រឹក** ហើយសិស្សានុសិស្សបានខិតខំប្រឹងប្រែងហាត់សម្តែងយ៉ាងសកម្ម ដើម្បីត្រៀមបង្ហាញនូវទេពកោសល្យដល់លោក លោកស្រីនិងក្រុមគ្រួសារពួកគេ សូមលោក លោកស្រីអញ្ជើញចូលរួមកម្មវិធីនេះទាំងអស់គ្នា។ សាលានឹងសម្រាកវិស្សមកាល បន្ទាប់ពីកម្មវិធីតន្ត្រីបញ្ចប់ឆ្នាំសិក្សា។

អ៊ិនធើណេសិនណល ស្គូល អហ្វ សៀមរាប
International School of Siem Reap

Field Trip!

# ដំណើរទស្សនៈកិច្ចសិក្សា


















សិស្សានុសិស្សពីថ្នាក់មត្តេយ្យកម្រិតខ្ពស់ដល់ថ្នាក់ទី៦បានចូលរួមដំណើរទស្សនៈកិច្ចសិក្សាទៅកាន់ទីតាំងជាច្រើននៅខេត្តសៀមរាប។

ពួកគេបានសិក្សា បន្ថែមលើមុខវិជ្ជាដែលបានរៀននៅក្នុងថ្នាក់ប្រកបដោយភាពរីករាយជាខ្លាំង នឹងជាកំរងអនុស្សាវរីយ៍ដ៏អស្ចារ្យមួយសម្រាប់ឆ្នាំសិក្សារបស់ពួកគេ។



